ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

សាលាភូមិន្ទរដ្ឋបាល

លេខ ១៣៩ ស.ភ.រ

# សេចក្តីជូនដំណឹង

សាលាភូមិន្ទរដ្ឋបាល សូមជម្រាបជូនដល់បេក្ខជនជាមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធទាំងអស់ដែលបានដាក់ពាក្យចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាព ដើម្បីចូលរៀនវគ្គក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមន្ត្រីមធ្យម ឆ្នាំសិក្សា ២០១៦ នៅសាលាភូមិន្ទរដ្ឋបាល ជ្រាបថាការប្រឡងនឹងប្រព្រឹត្តទៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៦ ចាប់ពីម៉ោង ៨:០០ ដល់ម៉ោង ១០:០០ព្រឹក នៅសាលាភូមិន្ទរដ្ឋបាល។

ប្រភេទវិញ្ញាសាដែលត្រូវកំណត់សម្រាប់ការប្រឡងត្រួតពិនិត្យសមត្ថភាពដើម្បីចូលរៀនវគ្គក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមន្ត្រីមធ្យម ឆ្នាំសិក្សា២០១៦ នៅសាលាភូមិន្ទរដ្ឋបាល រួមមាន៖

- វិញ្ញាសាប្រឡងដែលមានចម្លើយជ្រើសរើស (MCQ)៖
  - សេដ្ឋកិច្ច សង្គមកិច្ច
  - រដ្ឋបាលសាធារណៈ និងប្រព័ន្ធនយោបាយ
  - បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា និងអន្តរជាតិ
  - ចំណេះដឹងទូទៅវប្បធម៌ និងប្រវត្តិសាស្ត្រ
  - ការងារកំណែទម្រង់របស់រាជរដ្ឋាភិបាល

  } ៧៥ពិន្ទុ
- វិញ្ញាសាដំណោះស្រាយតាមករណី ២៥ពិន្ទុ

បេក្ខជនត្រូវមកដល់សាលាភូមិន្ទរដ្ឋបាល នៅវេលាម៉ោង ៧:៣០ព្រឹក ព្រមទាំងត្រូវមាន៖

១. អត្តសញ្ញាណបណ្ណមន្ត្រីរាជការស៊ីវិល ឬកងកម្លាំងប្រដាប់អាវុធ ឬធាយា ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

២. ប៊ិចពណ៌ខៀវ និង/ឬបន្ទាត់សម្រាប់ប្រើប្រាស់ពេលប្រឡង។

បេក្ខជនមិនត្រូវបានអនុញ្ញាតឱ្យយកឯកសារ ទូរស័ព្ទ ឧបករណ៍អេឡិចត្រូនិកផ្សេងៗចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត។

បេក្ខជនអាចចូលទៅក្នុងគេហទំព័ររបស់សាលា www.era.cambodia.gov.kh និងគេហទំព័ររបស់ក្រសួងមុខងារសាធារណៈ www.mcs.gov.kh ដើម្បីទទួលព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការប្រឡងនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦

នាយកសាលា

យក់ ម៉ុនណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល
លេខ......១៤០......ស.ភ.រ

# សេចក្តីណែនាំ
## ដល់បេក្ខជនក្នុងពេលប្រឡង

បេក្ខជនចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាពដើម្បីចូលរៀនវគ្គក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងមន្ត្រីមធ្យម ឆ្នាំ២០១៦ នៅសាលាភូមិន្ទរដ្ឋបាល ត្រូវគោរពអនុវត្តតាមការណែនាំដូចតទៅ៖

- ត្រូវចូលមកសាលាភូមិន្ទរដ្ឋបាលតាមច្រកទ្វារខាងក្រោយ និងយកភ្ជាប់មកជាមួយនូវលិខិតសម្គាល់ខ្លួន ឬអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬកងកម្លាំងប្រដាប់អាវុធ ឬថាយា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ព្រមទាំងប៊ិចខៀវ និងបូបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង
- ហាមយកជាប់មកជាមួយនូវឯកសារ ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ។ សាលាមិនទទួលខុសត្រូវរក្សាទុកនូវឯកសារ ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទនេះទេ
- ករណីមកយឺតម៉ោង "តិចជាង ១៥នាទី" ត្រូវសុំការអនុញ្ញាតពីប្រធានគណៈកម្មការប្រឡងជាមុនទើបអាចចូលប្រឡងបាន និងប្រគល់សន្លឹកកិច្ចការប្រឡងតាមម៉ោងកំណត់។ ការមកយឺតយ៉ាវលើស "១៥ នាទី" មិនអនុញ្ញាតឲ្យចូលប្រឡងជាដាច់ខាត។
- មិនត្រូវចូលបន្ទប់ប្រឡងមុនពេលហៅឈ្មោះ ត្រូវអង្គុយតាមលេខតុដែលបង្ហាញ ត្រូវសរសេរឈ្មោះ និងលេខតុលើក្បាលសន្លឹកកិច្ចការប្រឡងតាមការណែនាំរបស់អនុរក្ស និងប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សវិញ។ ការមិនប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្ស ចាត់ទុកជាអវត្តមាន។
- មិនត្រូវសរសេរក្នុងសញ្ញាខ្វែងនៃគ្រប់ទំព័រសន្លឹកកិច្ចការប្រឡង និងមិនត្រូវធ្វើគំនូសសញ្ញាធ្វើឲ្យដឹងអាគតដ្ឋាននៃសន្លឹកកិច្ចការប្រឡងឡើយ
- មិនត្រូវធ្វើសកម្មភាពលួចចម្លងតាមគ្រប់រូបភាព មិនប៉ុនប៉ងលួចចម្លង ឬចែករំលែកព័ត៌មានដល់អ្នកដទៃ។
- បេក្ខជនត្រូវដឹងអំពីសញ្ញាកណ្ដឹង៖
  + កណ្ដឹងទី១៖ ចូលបន្ទប់ប្រឡងបំពេញក្បាលសន្លឹកកិច្ចការប្រឡង
  + កណ្ដឹងទី២៖ ចាប់ផ្ដើមធ្វើវិញ្ញាសា
  + កណ្ដឹងទី៣៖ រំឭកថានៅសល់ ១៥នាទីទៀត ដល់ម៉ោងត្រូវប្រមូលសន្លឹកកិច្ចការប្រឡង
  + កណ្ដឹងទី៤៖ ប្រគល់សន្លឹកកិច្ចការប្រឡងឲ្យអនុរក្សជាកំហិត។

បេក្ខជនដែលមិនគោរពប្រតិបត្តិតាមការណែនាំខាងលើនេះ ឬគំរាមកំហែង ឬធ្វើឲ្យប៉ះពាល់ដល់កិត្តិយស ឬបូរណភាពរូបរាងកាយមន្ត្រីមានសមត្ថកិច្ចទាំងក្នុងបន្ទប់ប្រឡង និងក្រៅបន្ទប់ប្រឡង នឹងត្រូវបញ្ឈប់មិនឲ្យប្រឡងជាបន្ទាន់ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តនេះ និងហាមឃាត់មិនឲ្យចូលរួមប្រឡងនៅសាលាភូមិន្ទរដ្ឋបាលជាអចិន្ត្រៃយ៍ ព្រមទាំងទទួលខុសត្រូវតាមវិធានច្បាប់ជាធរមាន។

គណៈកម្មការ មានជំនឿយ៉ាងមុតមាំចំពោះស្មារតីទទួលខុសត្រូវ និងចូលរួមថែរក្សាឲ្យបាននូវភាពរលូននៃដំណើរការប្រឡងរបស់បេក្ខជន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៦

**នាយកសាលា**

**ឃត់ ម៉ិនណា**